# ជំនួបពិភាក្សាលើកទី ១ អំពី បរិស្ថាន និង ពលរដ្ឋ

1er **F**orum **E**co-**C**itoyen des **E**nfants de **P**hnom **P**enh
1st Phnom Penh Children's Eco-citizen Forum

**ថ្ងៃសៅរ៍ទី ១២ ខែ ឧសភា ឆ្នាំ ២០១២**
**សាលាបារាំងនៅភ្នំពេញ វិទ្យាល័យ រ៉ឺនេ ដេកាត**

fecepp2012.eklablog.com

## លទ្ធផលដែលទទួលបាន ៖

*សូមអរគុណចំពោះអ្នកទាំងអស់ដែលបានចូលរួមក្នុងជំនួបពិភាក្សាស្ដីអំពី បរិស្ថាន និង ពលរដ្ឋ។ នៅពេលនេះ យើងខ្ញុំសូមបង្ហាញពីលទ្ធផលដែលទទួលបាន។ ប្រសិនបើយើងទាំងអស់គ្នារួបរួមគ្នា យើងនឹងអាចធ្វើការជាមួយគ្នាយ៉ាងល្អប្រសើរ ដើម្បីអនាគតមួយប្រកបដោយនិរន្តរភាព។*

### ១. កាកសំណល់ និង ការបំពុល

- *បញ្ជ្រាបដល់អ្នកមនុស្សទាំងអស់ ដើម្បីអោយពួកគេបានដឹងពីរបៀបក្នុងការបង្កើតកាកសំណល់តិចជាងមុន និង មិនចោលសំរាមនៅតាមដងផ្លូវទៀត*
- *នៅគ្រប់ក្រុងទាំងអស់ យើងត្រូវដាក់អោយមានការញែកសំរាម ហើយនិងកម្មវិធីធ្វើអោយមានការប្រើប្រាស់ឡើងវិញនៅតាមបណ្ដាគ្រួសារ ក្នុងន័យថា ពលរដ្ឋម្នាក់ៗត្រូវតែអាចញែកសំរាមនៅផ្ទះរបស់ខ្លួនបាន*
- *ដាក់អោយមាននូវប្រព័ន្ធមួយគឺ "អ្នកណាបំពុលអ្នកនោះអ្នកបង់ថ្លៃ" ដែលនេះជាប្រព័ន្ធមួយសំរាប់រោងចក្រដែលផលិតកាកសំណល់ច្រើន និង ផាកពិន័យយ៉ាងធ្ងន់ធ្ងរក្នុងករណីដែលមានការបំពុលខ្លាំង*

- *ដាក់អោយមាននូវកម្មវិធីកាត់បន្ថយកាកសំណល់នៅតាមសហគ្រាស ដូចជា ៖ កាត់បន្ថយដប និង ថង់ផ្លាស្ទិកជាដើម*
- *លុបបំបាត់ថង់ផ្លាស្ទិកដែលបោះចោលបាននៅក្នុងក្រុង ដោយជំនួសមកវិញនូវក្រដាសដែលពេលខូចទៅគឺខូចដោយសារជីវសរីរាង្គ ឬក៏ជំនួសដោយថង់ផ្លាស្ទិកដែលអាចប្រើប្រាស់បានក្នុងរយៈពេលវែង*
- *កាត់បន្ថយចំនួនឡានដែលបំពុលខ្លាំង (ឡានធំៗ)*
- *បង្កើតការឃោសនាមួយក្នុងគោលបំណងកាត់បន្ថយការខ្ជះខ្ជាយអាហារ*

២. ទីធ្លាសាធារណៈនៅទីក្រុងភ្នំពេញ

- *ទីក្រុងភ្នំពេញត្រូវការទីធ្លាបៃតងច្រើន ជាពិសេសគឺដើមឈើនៅតាមផ្លូវ និង នៅតាមសួនឧទ្យាននានា ព្រោះថាដើមឈើទាំងនេះមិនត្រឹមតែជាម្លប់ទេ វាថែមទាំងជាសួតរបស់ទីក្រុងថែមទៀតផង*
- *បង្កើនចំនួន និង ការបែងចែកសួនឧទ្យាន នៅក្នុងក្រុង*
- *បង្កើតបន្ថែមនូវកន្លែងលេងសំរាប់កុមារ*

៣. ញ៉ាំល្អនៅទីក្រុងភ្នំពេញ

- *បញ្ជ្រាបដល់កសិករខ្មែរពីផលអវិជ្ជមាននៃការប្រើប្រាស់ជីគីមី និង លើកទឹកចិត្តពួកគេអោយប្រើប្រាស់ជីធម្មជាតិអោយបានច្រើន*
- *កាត់បន្ថយការនាំចូលផលិតផលគីមីសំរាប់បន្លែ និង ផ្លែឈើ*
- *គាំទ្រដល់ផលិតផលដែលដាំក្នុងស្រុក*
- *ផ្តល់ការគាំទ្រដល់កសិករដែលបង្កើតផលិតផលសរីរាង្គ និង កាត់បន្ថយការផលិតបន្លែផ្លែឈើដោយប្រើប្រាស់ជីគីមី។*

៤. សន្តិសុខនៅតាមដងវិថី

- *ដាក់អោយមាននូវកម្មវិធីមួយ ដើម្បីអោយប្រជាជនក្នុងទីក្រុងយល់ដឹងពីបញ្ហាសន្តិសុខតាមដងផ្លូវ និង ដើម្បីកាត់បន្ថយចំនួនគ្រោះថ្នាក់*
- *កុំពិសារជាតិស្រវឹងពេលបើកបរ*
- *កុំនិយាយទូរស័ព្ទពេលបើកបរ*
- *គោរពល្បឿនដែលបានកំណត់*
- *គោរពអ្នកថ្មើរជើង*
- *គោរពច្បាប់ចរាចរណ៍*
- *ចតយានយន្តនៅកន្លែងដែលសមស្រប*
- *អនុវត្តន៍ច្បាប់ចរាចរណ៍ដើម្បីបញ្ចៀសការកកស្ទះ ការបំពុល និង បញ្ហាការដកដង្ហើម*
- *ទីក្រុងភ្នំពេញអាចបង្កើតជាគេហទំព័រមួយដែលអាចអោយមនុស្សស្នើ "ការប្រើប្រាស់ឡានរួម" បាន។*
- *សំរួលផ្លូវដើម្បីអោយមានកន្លែងសំរាប់ជិះកង់បាន*

៥. បច្ចេកវិទ្យាថ្មីៗ

- *បញ្ជ្រាបអោយមនុស្សបានដឹងពីសារសំខាន់ក្នុងការបិទគ្រឿងអគ្គីសនី នៅពេលដែលយើងមិនប្រើប្រាស់វា ជាពិសេសគឺកុំព្យូទ័រ និង ទូរទស្សន៍ (គ្រាន់តែដាក់វាអោយរលត់សិនមិនគ្រប់គ្រាន់ទេ)*
- *បញ្ជ្រាបអោយមនុស្សទាំងអស់បានយល់ពីបញ្ហាទាក់ទងនឹងការផប់ផល់នឹងអ៊ីនធើនែត និង ការលេងល្បែងអេឡិកត្រូនិកខ្លាំងពេក*

៦. កីឡាក្នុងទីក្រុង

- *បង្កើនទីធ្លាសាធារណៈសំរាប់កីឡាអោយបានច្រើន (កន្លែងហាត់ប្រាណ កន្លែងលេងកីឡា ឧទ្យាន ... ហើយជំរុញអោយមានជំនួបកីឡាថ្នាក់ក្រុងអោយបានច្រើន*
- *ដាក់ពាក្យស្លោកឃោសនានៅទូទាំងទីក្រុង ដើម្បីពន្យល់ពីសារប្រយោជន៍សំរាប់យុវជនក្នុងការលេងកីឡា*
- *ផ្តល់លទ្ធភាពអោយបានច្រើនដល់យុវជន ដើម្បីអោយពួកគេបានចូលរួមការប្រកួតកីឡាថ្នាក់អន្តរជាតិ*
- *អោយជនពិការបានចូលរួមលេងកីឡាដោយសេរី*

៧. សាមគ្គីភាព និង បរិស្ថាន

- *ធ្វើយ៉ាងណាអោយកុមារទាំងអស់បានទទួលនូវការអប់រំមួយប្រកបប្រកបដោយគុណភាព ទោះជាពួកគេមានក្តី ឬក្រក្តី*
- *អភិវឌ្ឍន៍ការធ្វើដំណើរជារួម ជាពិសេសគឺឡានសំរាប់ទៅសាលា*
- *លើកទឹកចិត្តដល់អង្គការក្រៅរដ្ឋាភិបាលក្នុងការអភិវឌ្ឍគំរោងបរិស្ថាន និងផ្សព្វផ្សាយចំណេះដឹងរបស់ពួកគេដល់កុមារ*
- *បង្កើតកម្មវិធីដើម្បីជួយកុមារនៅតាមផ្លូវអោយមានកន្លែងជ្រក និង ទទួលបានការអប់រំមួយល្អ*
- *បង្កើនចំនួនបង្គន់សាធារណៈ និង ជំរុញអោយមនុស្សចេះប្រើប្រាស់បង្គន់ទាំងនោះ*
- *ជួយ និង សំរួលដល់ការសន្ទនា និង ទំនាក់ទំនងរវាងសាលាសាធារណៈ សាលាអន្តរជាតិ និង សាលាឯកជន*
- *សំរួលដល់ការបង្កើតអោយមានក្រុមប្រឹក្សាថ្នាក់ក្រុងសំរាប់កុមារក្នុងទីក្រុងភ្នំពេញ*